**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា**
**ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ**
**មជ្ឈមណ្ឌលអប់រំ**
**440 NORTH BROAD STREET, ជាន់ទី២ ច្រកចូល C**
**PHILADELPHIA, PENNSYLVANIA 19130**

Renee Queen Jackson — ទូរស័ព្ទ៖ (២១៥) ៤០០-៤២៧០
*នាយិការង* — ទូរសារ៖ (២១៥) ៤០០-៤២៧១

# ប្រុងប្រយ័ត្នផ្នែកសន្តិសុខ

មាតាបិតា៖

ដោយសារព្រឹត្តការណ៍ដែលបានកើតឡើងថ្មីៗ នៅក្នុងសាលារបស់យើង វិធីសាស្រ្តដែលទាក់ទងនឹង ការចូលរៀន និងការចេញពីសាលា ប្រហែលជាមានការផ្លាស់ប្តូរ។ សូមចងចាំថា វិធីសាស្រ្តទាំងនេះត្រូវបានគេយកមកអនុវត្ត ដើម្បីធ្វើយ៉ាងណាឲ្យមានសន្តិសុខសម្រាប់ក្មេងទាំងអស់ មិនមែនដើម្បីផ្តល់ការលំបាកដល់លោកអ្នកនោះទេ។

**ច្បាប់នៃការ ជូនសិស្ស ចេញពីរៀន និង ការចូលរៀន**

- មាតាបិតាត្រូវប្រគល់បញ្ជីឈ្មោះមនុស្សពេញវ័យ ដែលអាចមកទទួលកូនរបស់លោកអ្នក ឲ្យបានច្បាស់លាស់។
- អ្នកដែលជូនសិស្សទាំងអស់ ត្រូវមានអាយុ ១៨ឆ្នាំ ឬចាស់ជាងនេះ។ **ដោយគ្មានការលើកលែង**!
- មាតាបិតា ត្រូវផ្តល់ព័ត៌មានឲ្យអ្នកដែលមើលថែក្មេង។
- បុគ្គលិកនៃកន្លែងមើលថែក្មេង ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ នៅពេលមកទទួលយកក្មេង។
- មាតាបិតា អ្នកជូន និង បុគ្គលិកនៃកន្លែងមើលថែក្មេង ត្រូវចុះហត្ថលេខានៅក្នុងសៀវភៅអ្នកជូនក្មេង ពេលចូល និងពេលចេញ។ **ដោយគ្មានការលើកលែង**!
- មាតាបិតាត្រូវជម្រាបប្រាប់គ្រូ គ្រប់ពេលដែលក្មេងចេញពីសាលា និងឈ្មោះអ្នកដែលមកទទួលយកក្មេង។
- ទាំងនេះគឺជាសេចក្តីណែនាំជាទូទៅ សម្រាប់កម្មវិធីមុនថ្នាក់មត្តេយ្យទាំងអស់។ នាយកសាលា នឹងបង្កើតសេចក្តីណែនាំដែលជាក់លាក់ សម្រាប់សាលានីមួយៗ ហើយព័ត៌មានទាំងនោះនឹងជម្រាបទៅមាតាបិតា។ មាតាបិតានឹងគោរពតាម វិធីសាស្រ្តទាំងនោះ។

មាតាបិតាទាំងឡាយ ដើម្បីធ្វើយ៉ាងណារក្សាសុវត្ថិភាពរបស់សិស្សទាំងអស់ឲ្យបាន សំខាន់ត្រូវធ្វើយ៉ាងណាឲ្យកូនរបស់លោកអ្នក មកដល់សាលា និង មកទទួលកូនរបស់លោកអ្នក ឲ្យបានទាន់ពេលវេលា។

សូមគត់សម្គាល់៖ គេមិនអនុញ្ញាតឲ្យក្មេងទៅជាមួយអ្នកជូនណា ដែលគ្មានឈ្មោះ និងគ្មានអត្តសញ្ញាណប័ណ្ណ នៅក្នុងឯកសារ ដោយគ្មានការផ្តល់ដំណឹងជាមុន នោះទេ។